# ក្របខណ្ឌភាពជាដៃគូរបស់ធនាគារពិភពលោកប្រចាំកម្ពុជា សម្រាប់ឆ្នាំ២០២៥-២០២៩

## កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំពិគ្រោះយោបល់ជាមួយវិស័យឯកជន

## ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣

## សណ្ឋាគារ Raffles Le Royal, ភ្នំពេញ

នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣ ការិយាល័យរបស់ធនាគារពិភពលោកប្រចាំនៅកម្ពុជា បានបើកកិច្ចប្រជុំពិគ្រោះយោបល់ លើកទី៣ ជាមួយតំណាងរបស់វិស័យឯកជន ដើម្បីពិភាក្សាប្រមូលគំនិតសម្រាប់រៀបចំឯកសារ ក្របខណ្ឌភាពជាដៃគូ ប្រចាំប្រទេសកម្ពុជា សម្រាប់ឆ្នាំ២០២៥-២០២៩ ដែលសរសេរកាត់ជាអង់គ្លេសថា CPF។ កិច្ចប្រជុំនេះមានការចូលរួម របស់តំណាង ៣៥នាក់ មកពីវិស័យឯកជន (សូមមើលឧបសម្ព័ន្ធភ្ជាប់មកជាមួយ)។

**<u>ចំណុចសំខាន់ៗដែលបានពិភាក្សា៖</u>**

**ការផ្តោតលើអន្តរផ្នែកក្រោមមូលបទអភិបាលកិច្ចក្នុង CPF បានទទួលការយកចិត្តទុកដាក់ និងគាំទ្រច្រើន ពីសំណាក់អ្នកចូលរួម។**

- អ្នកចូលរួមបានផ្តោតការពិភាក្សាលើភាពចាំបាច់ឱ្យមានការអនុវត្តឱ្យម៉ឺងម៉ាត់ថែមទៀត នូវគោលនយោបាយរបស់រដ្ឋាភិបាលដែលមានស្រាប់ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងបង្កើនភាពប្រាកដប្រជាសម្រាប់ដំណើរការធ្វើធុរកិច្ច និងការចំណាយពាក់ព័ន្ធ។ ពួកគាត់បានលើកឡើងដែរថា ការអនុវត្តគោលនយោបាយ និងបទប្បញ្ញត្តិ គ្មានសង្គតិភាព បានបង្កឱ្យមានភាពមិនច្បាស់លាស់សម្រាប់ធុរកិច្ច ដែលសុទ្ធតែជារឿងសៅហ្មងសម្រាប់អ្នកវិនិយោគអន្តរជាតិ និងបន្ទុចបង្អាក់ដល់កំណើនវិស័យឯកជនក្នុងស្រុក។
- អ្នកចូលរួមបានលើកឡើងថា ជារឿងមានប្រយោជន៍ កាលណាមានព័ត៌មាន, ការវិភាគ និងទិន្នន័យបន្ថែមទៀត ដើម្បីធានាឱ្យមានការអនុវត្តបទប្បញ្ញត្តិធុរកិច្ចប្រកបដោយសង្គតិភាព។
- អ្នកផ្តល់ចម្លើយមួយចំនួនបានកត់សម្គាល់លើបញ្ហាជាមួយភាពស្មុគស្មាញនៃប្រព័ន្ធពន្ធដារ ដែលកន្លែងនៅក្នុងប្រព័ន្ធខ្លះជាកម្មវត្ថុសម្រាប់ការបកស្រាយផ្សេងៗគ្នា ហើយគេត្រូវចំណាយពេលច្រើនណាស់ដើម្បីស្វែងយល់។
- អ្នកចូលរួមជាច្រើនបានលើកឡើងថា ការបង្កើនស្វ័យប្រវត្តិកម្ម និងឌីជីថលកម្មសម្រាប់ការចុះឈ្មោះអាជីវកម្ម និងការផ្តល់សេវាពាក់ព័ន្ធសំខាន់ៗ នឹងជួយកាត់បន្ថយការចំណាយក្រៅផ្លូវការ។
- មានការកត់សម្គាល់ផងដែរថា កង្វល់អំពីចំណុចនេះក៏ត្រូវបានលើកឡើងដែរ នៅក្នុងវេទិកាសាធារណៈ និងឯកជនដែលរដ្ឋាភិបាលកម្ពុជាបានធ្វើឡើង កាលពីខែវិច្ឆិកា ឆ្នាំ២០២៣ កន្លងទៅ។

**មានការលើកឡើងនូវសំណើជាច្រើនសុំឱ្យបង្កើនការធ្វើការពាក់ព័ន្ធគ្នា រវាងធនាគារពិភពលោក និងវិស័យឯកជន ឱ្យបានកាន់តែច្រើន និងញឹកញាប់ជាងមុន។**

- អ្នកចូលរួមបានសម្តែងទឹកចិត្តចង់ខ្លាំង ក្នុងការស្វែងយល់ឱ្យបានកាន់តែច្បាស់ថែមទៀតថា តើវិស័យឯកជនអាចធ្វើបានដូចម្តេចខ្លះដើម្បីជួយដល់ លទ្ធផលរំពឹងទុកកម្រិតខ្ពស់ (High Level Outcomes/HLO) របស់ CPF។

- ការធ្វើការពាក់ព័ន្ធកាន់តែញឹកញាប់ជាមួយធនាគារពិភពលោក ត្រូវបានអ្នកចូលរួមស្នើឡើង រួមជាមួយនឹងការសង្កត់ធ្ងន់កាន់តែខ្លាំងលើតួនាទីរបស់វិស័យឯកជននៅក្នុង CPF។

## លទ្ធផលរំពឹងទុកកម្រិតខ្ពស់ (High Level Outcomes/HLO) របស់ CPF និងការផ្តោតលើធនធានមនុស្ស និងការអប់រំទទួលបានការគាំទ្រទូលំទូលាយ។

- អ្នកចូលរួមបានសម្តែងការគាំទ្រចំពោះការកសាងជំនាញ និងការអប់រំ។ ពួកគេបានលើកឡើងថា ធនាគារពិភពលោកគួរធ្វើថែមទៀតក្នុងការជួយដល់ផ្នែកអប់រំ និងក្នុងការឆ្លើយតបទៅនឹងការធ្លាក់ចុះគុណភាពនៃការអប់រំកម្រិតឧត្តមសិក្សា។ ទាក់ទងចំណុចនេះ ពួកគាត់បានធ្វើការកត់សម្គាល់មួយថា គួរតែមានការសិក្សាស្រាវជ្រាវមួយ ដើម្បីឈ្វេងយល់ឱ្យបានកាន់តែច្បាស់ អំពីកត្តានានាដែលញ៉ាំងឱ្យសិស្សឈប់រៀន ដូចជាសម្ពាធនៃការខ្វះថវិកាក្នុងគ្រួសារជាដើម។
- តំណាងវិស័យឯកជនបានកត់សម្គាល់ថា ការអប់រំ និងធនធានមនុស្ស មានសារៈសំខាន់ក្នុងការលើកកម្ពស់សមត្ថភាពប្រកួតប្រជែងនៅក្នុងប្រទេសកម្ពុជា ហើយពួកគេបានស្នើឡើងថា វាគួរតែជាអាទិភាពសម្រាប់កិច្ចសហប្រតិបត្តិការគ្នារវាងធនាគារពិភពលោក និងវិស័យឯកជន។
- សម្រាប់ការកំណត់ថាតើវិស័យឯកជនអាចមានតួនាទីអ្វីខ្លះ ក្នុងការបង្កើនឱ្យប្រសើរឡើងនូវលទ្ធផលក្នុងវិស័យអប់រំ, តំណាងវិស័យឯកជនបានស្នើឱ្យមានការពិភាក្សា និងកិច្ចសហការគ្នាឱ្យបានកាន់តែញឹកញាប់ ជាមួយធនាគារពិភពលោក។

## មានសំណើសុំឱ្យបង្កើនការរីកចម្រើនថែមទៀត នៅក្នុងជំនាញបច្ចេកទេស និងជំនាញវិជ្ជាជីវៈ។

- អ្នកចូលរួមបានសម្តែងការគាំទ្រដល់ការយកចិត្តទុកដាក់របស់ធនាគារពិភពលោក លើការអប់រំកម្រិតឧត្តមសិក្សា ប៉ុន្តែពួកគេក៏បានគូសបញ្ជាក់ដែរ ពីតម្រូវការឱ្យមានការជួយដល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ដែលមានមនុស្សចុះឈ្មោះតិច នេះបើតាមការឱ្យដឹងពីតំណាងមកពីវិស័យកាត់ដេរ។
- មានការលើកឡើងយោបល់ស្នើឱ្យធនាគារពិភពលោក ធ្វើការសម្របសម្រួលឱ្យកាន់តែជិតស្និទ្ធជាមួយវិស័យឯកជន ដើម្បីគិតគូរកមើលថាតើជំនាញណាខ្លះ ដែលមានប្រយោជន៍ជាងគេសម្រាប់ការជួយគាំទ្រ។
- មុខរបរពាណិជ្ជកម្ម និងជំនាញ ដូចជាជំនាញជាងជួសជុលប្រព័ន្ធទឹក, ជាងវិស្វកម្ម និងជាងអគ្គិសនី ត្រូវបានច្បិចចំៗថាសុទ្ធតែជាជំនាញដែលជួយជំរុញអាជីវកម្មសហគ្រាសធុនតូច និងមធ្យម (SMEs) ដែលជាការពង្រីកសកម្មភាពសេដ្ឋកិច្ច។ ដូច្នេះ ការអភិវឌ្ឍឱ្យបានកាន់តែប្រសើរឡើងនូវជំនាញក្នុងវិស័យទាំងនេះ ត្រូវបានចាត់ទុកថាជាឱកាសសម្រាប់រកចំណូលសាធារណៈ។
- មានការលើកយោបល់ឡើងថា ធុរកិច្ចនៅក្នុងប្រទេសកម្ពុជាគួរវិនិយោគឱ្យកាន់តែមានប្រសិទ្ធភាព លើការបណ្តុះបណ្តាលកម្មករក្នុងស្រុក ប៉ុន្តែចាំបាច់ត្រូវមានគ្រូបណ្តុះបណ្តាលដែលមានគុណភាពខ្ពស់។
- អ្នកចូលរួមបានយោងទៅរកការវិភាគក្នុងឯកសារ Systematic Country Diagnostic របស់ធនាគារពិភពលោក ដែលបានធ្វើការសន្និដ្ឋានថា គំរូកំណើនសេដ្ឋកិច្ចរបស់កម្ពុជាកំពុងតែមានការប្រែប្រួលទ្រង់ទ្រាយ ហើយពួកគាត់បានស្នើសុំកិច្ចសហការបន្ថែមជាមួយធនាគារពិភពលោក រួមជាមួយនឹងការសិក្សាស្រាវជ្រាវផង អំពីការថាតើ មាន

វិធីណាខ្លះដែលវិស័យឯកជនអាចជួយបានក្នុងការធ្វើបរិវត្តន៍កម្មនៃសំណុំជំនាញ ជាមួយនឹងការសិក្សាបន្ថែមថា តើជំនាញណាខ្លះ ដែលសមស្របបំផុតសម្រាប់ឆ្លើយតបទៅនឹងឱកាសនាពេលអនាគត។

- អ្នកឆ្លើយសំណួរជាច្រើនបានលើកឡើងពីភាពចាំបាច់ត្រូវផ្ដោតការយកចិត្តទុកដាក់លើគុណភាពនៃការអប់រំ និង វគ្គបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដែលកំពុងមានស្រាប់ក្នុងកម្មវិធីសិក្សាផង កុំផ្ដោតលើលទ្ធភាពទទួលបានការបណ្ដុះបណ្ដាល TVET តែមួយមុខ។
- មានការលើកយោបល់ថា ចាំបាច់ត្រូវមានឧស្សាហកម្មបន្ថែមទៀតនៅខាងចុងខ្សែ (downstream) ដើម្បីបង្កើតការងារឱ្យបានគ្រប់គ្រាន់សម្រាប់ស្រូបយកមនុស្សចូលធ្វើការ នៅពេលបរិមាណនៃការអប់រំ និងជំនាញរំពឹងថានឹងការកើនឡើងនាពេលខាងមុខ។ មានសំណើមួយសុំឱ្យធនាគារពិភពលោកផ្ដល់យោបល់អំពីឱកាសទាក់ទងចំណុចនេះ ហើយធ្វើការវិភាគមួយសម្រាប់ជាយកជាមូលដ្ឋានផ្ដល់ការគាំទ្រផងដែរ។

**មានការពិភាក្សាយ៉ាងផុលផុស អំពីការយល់ឃើញរបស់វិស័យឯកជន អំពីអាទិភាពជុំវិញការប្រែប្រួលអាកាសធាតុ។**

- អ្នកចូលរួមបានធ្វើការកត់សម្គាល់ថា សហគ្រាសក្នុងស្រុកត្រូវយល់ដឹងឱ្យបានកាន់តែច្បាស់ថាតើ ចរន្តប្រែប្រួលនៃទីផ្សារពិភពលោកឆ្ពោះទៅរកការធ្វើជំនួញដោយមិនបញ្ចេញកាបូន (decarbonization) អាចជះផលប៉ះពាល់បែបណាខ្លះដល់ការនាំចេញរបស់ធុរកិច្ចនៅក្នុងស្រុក ដូច្នេះការចំណាយចាំបាច់ពាក់ព័ន្ធការកាត់បន្ថយបំភាយកាបូនគឺកាន់តែច្បាស់។
- តំណាងមកពីវិស័យធនាគារបានលើកឡើងបញ្ហានានា ជុំវិញកម្ចីមិនដំណើរក្នុងប្រទេសកម្ពុជា។ ពួកគេបានស្នើឱ្យមានការដោះស្រាយបញ្ហានេះ ដោយធានាយ៉ាងណាកុំឱ្យការងាកទៅរកការធ្វើហិរញ្ញប្បទានបៃតង នឹងមិនដាក់ទម្ងន់ថែមលើបញ្ហាកម្ចីមិនដំណើរការទេ។
- តំណាងមកពីឧស្សាហកម្មកាត់ដេរ បានលើកឡើងអំពីការងារដើម្បីបង្កើនប្រសិទ្ធភាពថាមពល រួមទាំងសវនកម្មថាមពលផង និងជម្រើសដើម្បីកាត់បន្ថយចំណាយថ្លៃដើមលើថាមពល ឬការធ្វើអន្តរកម្មទៅប្រើថាមពលកកើតឡើងវិញ។ ពួកគេបានលើកឡើងពីការផ្ដល់ហិរញ្ញប្បទានថាវាជាបញ្ហាមួយ កាលណានិយាយអំពីការងាកទៅរកការប្រើថាមពលកកើតឡើងវិញ និងការគាំទ្រសម្រាប់ "កម្ចីបៃតង"។ មានការបញ្ចេញយោបល់ថា ការផ្ដល់កម្ចីក្នុងអត្រាការប្រាក់ទាប ជាមួយនឹងតម្រូវការដាក់វត្ថុបញ្ចាំក្នុងកម្រិតតិចតួច អាចជួយដោះស្រាយបញ្ហានេះបាន។
- អ្នកចូលរួមផ្សេងទៀតបានកត់សម្គាល់ពីបញ្ហាខ្វះចន្លោះនៅក្នុងកិច្ចការពារ សម្រាប់ការផ្ដល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុសម្រាប់ការវិនិយោគបៃតង ដូច្នេះគួរតែធ្វើកិច្ចការនានាដើម្បីកំណត់ប្រការលើកទឹកចិត្តឱ្យមានប្រសិទ្ធភាពជាងមុនសម្រាប់ការធ្វើហិរញ្ញប្បទានបៃតង។

**លទ្ធផលរំពឹងទុកកម្រិតខ្ពស់ (HLO) របស់ CPF ស្ដីពីភាពប្រកួតប្រជែង ទទួលបានការគាំទ្រ។**

- អ្នកចូលរួមមួយចំនួនបានលើកឡើងថា ការចំណាយលើឡូហ្ស៊ីស្ទិក ដែលមានទំហំធំជាងថ្លៃចំណាយលើថាមពលសម្រាប់ធ្វើធុរកិច្ច មានផលប៉ះពាល់យ៉ាងធំលើការប្រកួតប្រជែង ដូច្នេះហើយ HLO 2 គួរតែផ្ដោតជាពិសេសទៅលើបញ្ហាឡូហ្ស៊ីស្ទិក។

- ភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន (PPPs) ត្រូវបានលើកឡើងថាជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយក្នុងការកែលម្អសមត្ថភាពឡូហ្ស៊ីស្ទិកឱ្យប្រសើរឡើង។ មានការស្នើឱ្យមានជំនួយបន្ថែមទៀតដែរសម្រាប់សមត្ថភាពស្ថាប័ននៃ PPPs និងដើម្បីជំរុញកំណើនអ្នកវិនិយោគក្នុងស្រុក តាមរយៈការកសាងសមត្ថភាព និងការងារវិភាគដើម្បីគាំទ្រគំរូ PPP។
- គោលនយោបាយ និងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ (FINTECH) ទទួលបានបានការកត់សម្គាល់ថាជាសញ្ញាវិជ្ជមាន ហើយពង្រីកឌីជីថលកម្មកាន់តែធំ និងលទ្ធភាពទទួលបានការប្រើប្រាស់វា ត្រូវបានរំលេចថាជាអាទិភាពមានសក្តានុពលមួយសម្រាប់វិស័យនេះ។

**កិច្ចការវិភាគរបស់ធនាគារពិភពលោកទទួលបានការគាំទ្រ និងវាយតម្លៃខ្ពស់ ពីសំណាក់អ្នកចូលរួម។**

- អ្នកចូលរួមបានលើកឡើងម្តងហើយម្តងទៀតអំពីសារប្រយោជន៍ និងអត្ថប្រយោជន៍វិសេសវិសាល នៃការសិក្សាស្រាវជ្រាវរបស់ធនាគារពិភពលោក ដោយហៅវាថា "គ្មានអ្វីមកប្រៀបផ្ទឹមបាន"។
- ចំណុចទាំងនេះត្រូវបានចាត់ទុកថាជាសម្បត្តិដ៏សំខាន់ សម្រាប់វិស័យឯកជនយកទៅប្រើប្រាស់ដោយប្រុងប្រយ័ត្នសម្របតាមតម្រូវការរៀងៗខ្លួន។
- មានសំណើត្រូវបានធ្វើឡើងសុំឱ្យធ្វើការវិភាគបន្ថែមទៀតលើគំរូ PPP, ថាតើមានវិធីណាខ្លះដែលអ្នកវិនិយោគក្នុងស្រុកអាចបង្កើនភាពជាដៃគូសាធារណៈ និងឯកជន (PPPs) និងអត្ថប្រយោជន៍ធុរកិច្ចសម្រាប់ការទូទាត់ថ្លៃក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ និងថាតើវាអាចជំរុញសកម្មភាពក្នុងស្រុកបានដោយវិធីណាខ្លះ។

**ចំណុចផ្សេងទៀត៖**

- អ្នកចូលរួមបានកត់សម្គាល់ថា ហិរញ្ញប្បទានរបស់ក្រុមធនាគារពិភពលោកដល់សហគ្រាសធុនតូច និងមធ្យម មិនគ្រប់គ្រាន់ទេ ហើយវាគួរត្រូវបានពង្រីកថែមទៀត ដើម្បីគាំទ្រដល់ការរីកចម្រើននៃសហគ្រាសខ្នាតតូច។
- ទាក់ទងនឹងស្ថិរភាពហិរញ្ញវត្ថុ និងការធ្វើឱ្យប្រសើរឡើងដល់បរិយាបន្នផ្នែកហិរញ្ញវត្ថុ អ្នកចូលរួមបានស្នើសុំឱ្យមើលគំនិតផ្តួចផ្តើមដែលបានស្នើឡើង និងពិគ្រោះយោបល់ជាមួយពួកគាត់ផង ថាតើក្រុមធនាគារពិភពលោកគ្រោងនឹងដោះស្រាយបញ្ហាប្រឈមទាំងនេះដោយរបៀបណាខ្លះ។
- ស្តីពីបរិយាបន្នផ្នែកហិរញ្ញវត្ថុ អ្នកចូលរួមបាននិយាយយោងទៅលើវឌ្ឍនភាពល្អផ្នែកគោលនយោបាយ និងបទប្បញ្ញត្តិក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ប៉ុន្តែគេក៏បានរំលឹកដែរថា នៅមានកិច្ចការច្រើនទៀតដែលត្រូវធ្វើ។

ឧបសម្ព័ន្ធ៖

| ចំនួនអ្នកចូលរួម | អង្គភាពមានវត្តមាន |
|---|---|
| មកពី៣២ស្ថាប័ន | ABA Bank<br>ACLEDA Bank<br>AmCham<br>AMRET<br>Cambodia Rice Federation Amru Rice (Cambodia) Co., Ltd<br>Association of Banks in Cambodia (ABC)<br>Cambodia Australia Partnership for Resilient Economic Development (CAPRED)<br>Dai Ichi life insurance, IAC BOM member Cambodia Insurance Association<br>Cambodia Microfinance Association (CMA)<br>Cambodia Securities Exchange (CSX)<br>Credit Bureau of Cambodia (CBC)<br>Credit Guarantee Corporation of Cambodia (CGCC)<br>Hatha Bank<br>Prudential<br>Real Estate Business & Pawnshop Regulator (RPR)<br>SME Bank<br>TAFTAC (Textile, Apparel, Footwear & Travel Goods Association in Cambodia) _Former GMAC<br>Wing Bank Cambodia Plc<br>Worldbridge<br>Sathapana Bank<br>Greenway<br>Canadia Bank<br>CIMB<br>KPMG<br>Elite Group<br>Kirisu Farm<br>COMREDA<br>Auskhmer Import Export Co., Ltd<br>Bridge Bank Plc.<br>MEF |